**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកពោធិ៍សាត់**
លេខ: ១១៦ .រពស.សជណ

ថ្ងៃពុធ ៦កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ពោធិ៍សាត់,ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសនិស្សិតដែលមានបំណងធ្វើកម្មសិក្សានៅរដ្ឋាករទឹកពោធិ៍សាត់

រដ្ឋាករទឹកពោធិ៍សាត់ត្រូវការជ្រើសរើសនិស្សិតដែលជិតបញ្ចប់ ឬបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដើម្បីទទួលបានឱកាសធ្វើកម្មសិក្សារយៈពេល០៣ខែ នៅរដ្ឋាករទឹកពោធិ៍សាត់ចំនួន០៣រូប ដែលមាន០៣ផ្នែកដូចខាងក្រោម៖

| | |
|---|---|
| ១. ការងារផ្នែកវិភាគគុណភាពទឹក | ០១រូប |
| ២. ការងារផ្នែកគូសប្លង់ ( AutoCAD, ArcGIS, Civil 3D,....) | ០១រូប |
| ៣. គ្រប់គ្រងរបាយការណ៍អាជីវកម្ម( រដ្ឋបាលទូទៅ ) | ០១រូប |

- បេក្ខជន បេក្ខនារី ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖
  - បេក្ខជន បេក្ខនារី ត្រូវជានិស្សិតឆ្នាំទី៤ឡើង ឬបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងបានសិក្សាលើមុខវិជ្ជាណាមួយ ឬមុខវិជ្ជាប្រហាក់ប្រហែលនៃការងារណាមួយពាក់ព័ន្ធនឹងផ្នែកទាំង៣ខាងលើ
  - អាចប្រើប្រាស់កុំព្យូទ័របាន ( កម្រិតមូលដ្ឋាន ដូចជា៖ Word and Excel )
  - ឧស្សាហ៍ ព្យាយាម អំណត់ ស្មោះត្រង់ និងទទួលខុសត្រូវខ្ពស់
  - មានភាពរួសរាយរាក់ទាក់ សាមគ្គីភាព និងមានសីលធម៌ល្អ

បេក្ខជន បេក្ខនារី ដែលមានចំណាប់អារម្មណ៍ សូមមកដាក់ប្រវត្តិរូប (មានបិទរូបថត) នៅរដ្ឋាករទឹកពោធិ៍សាត់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

- **<u>ទីកន្លែងទទួលពាក្យ- ពេលវេលាទំនាក់ទំនងនិងកាលបរិច្ឆេទឈប់ទទួលពាក្យ</u>**

-ទីកន្លែងទទួលពាក្យ ៖ នៅរដ្ឋាករទឹកពោធិ៍សាត់( ការិយាល័យរដ្ឋបាល )ស្ថិតនៅភូមិពោធិ៍តាក្មួយ សង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។

-ពេលវេលាទំនាក់ទំនង៖-ពេលព្រឹកពីម៉ោង ៧:០០នាទី - ១១:៣០នាទី
-ពេលរសៀលពីម៉ោង ១៤:០០នាទី - ១៧:០០ ។

**-កាលបរិច្ឆេទនៃការឈប់ទទួលពាក្យៈថ្ងៃទី០៥ ខែសីហា ឆ្នាំ ២០២៥ ។**

បញ្ជាក់៖

- បេក្ខនារី និងបេក្ខជនមានពិការភាពត្រូវបានលើកទឹកចិត្ត និងផ្តល់អាទិភាពសម្រាប់ការជ្រើសរើសនេះ។
- បេក្ខជន បេក្ខនារីដែលត្រូវបានជ្រើសរើសដើម្បីធ្វើកម្មសិក្សានឹងទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋាករទឹកពោធិ៍សាត់ក្នុងរយៈពេលនៃកម្មសិក្សា។
- ព័ត៌មានបន្ថែម បេក្ខជន បេក្ខនារីអាចទំនាក់ទំនងនៅការិយាល័យរដ្ឋបាលនៃរដ្ឋាករទឹកពោធិ៍សាត់ ឬអាចទំនាក់ទំនងតាមរយៈលេខតេឡេក្រាម៖ <u>098 706 290/017</u> 663 896។

**អគ្គនាយក**

**ស៊ៀង សេងពុទ្ធា**